**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ខេត្តមណ្ឌលគិរី**
**ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម**

*លេខ.................កអសក.មគ*

**សូមគោរពជូន**
**លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តមណ្ឌលគិរី**

**កម្មវត្ថុ** ៖ របាយការណ៍ឆមាសទី ០២ ឆ្នាំ២០១៧ (គិតត្រឹមថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៧ )
**ជូនភ្ជាប់** ៖ តារាងបច្ចុប្បន្នភាពសហគមន៍កសិកម្មចំនួន..........................................................០១ច្បាប់

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងជូនភ្ជាប់ខាងលើនេះ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូនលោកប្រធាន មេត្តាជ្រាបៈ អំពីសកម្មភាពការងារ ដែលការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម បានធ្វើបច្ចុប្បន្នភាពសហគមន៍កសិកម្ម ដើម្បីតាមដានដំណើការប្រព្រឹត្តទៅ និងការរីកចំរើនរបស់សហគមន៍កសិកម្មទទួលបានលទ្ធផលដូចខាងក្រោម ៖

I. **សហគមន៍កសិកម្ម**

បច្ចុប្បន្ននៅក្នុងខេត្តមណ្ឌលគិរី មានសហគមន៍កសិកម្មសរុបចំនួន ០៦សហគមន៍កសិកម្ម ដែលក្នុងនោះនៅស្រុកកោះញែក មានសហគមន៍កសិកម្មសរុបចំនួន ០៣ និងនៅក្រុងសែនមនោរម្យ មានសហគមន៍កសិកម្មសរុបចំនួន ០២ ។ សហគមន៍កសិកម្មទូទាំងខេត្ត បានកំពង់ធ្វើប្រត្តិបត្តិការលើមុខរបរតែមុខ គឺឥណទានកសិកម្ម ដែលហេតុធ្វើឲ្យសហគមន៍កសិកម្ម មានភាពរីកចំរើនយឺត ។

១. សហគមន៍អភិវឌ្ឍន៍កសិកម្មកោះញែក បច្ចុប្បន្នមានអសយដ្ឋាននៅភូមិស្រែហ៊ុយ ឃុំស្រែហ៊ុយ ស្រុកកោះញែក ខេត្តមណ្ឌលគិរី ដែលមានសមាជិកសរុបចំនួន ៦២នាក់ ក្នុងនោះស្រីសរុបចំនួន ៣០នាក់ ភាគហ៊ុនសរុបចំនួន ៦២ភាគហ៊ុន និងមានទុនសហគមន៍កសិកម្មសរុបចំនួន ១៩,១៩០,០០០ រៀល (ដប់ប្រាំបួនលានដប់ប្រាំបួនម៉ឺនរៀលគត់ ) ។

២. សហគមន៍អភិវឌ្ឍន៍កសិកម្មសិរីមានរិទ្ធ បច្ចុប្បន្នមានអសយដ្ឋាននៅភូមិ សិរីមានរិទ្ធ ឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគិរី ដែលមានសមាជិកសរុបចំនួន ៥០នាក់ ក្នុងនោះស្រីសរុបចំនួន ៣៧នាក់ ភាគហ៊ុនសរុបចំនួន ១៨៣ភាគហ៊ុន និងមានទុនសហគមន៍កសិកម្មសរុបចំនួន ១៦២,៧៥៩,០០០ រៀល (មួយរយហុកសិបពីរលានប្រាំបីរយហាសិបប្រាំបួនពាន់រៀលគត់ ) ។

៣. សហគមន៍អភិវឌ្ឍន៍កសិកម្ម កាហ្វេ-ម្រេច មណ្ឌលគិរី បច្ចុប្បន្នមានអសយដ្ឋាននៅភូមិកណ្តាល សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ដែលមានសមាជិកសរុបចំនួន ៨៥នាក់ ក្នុងនោះស្រីសរុបចំនួន ១២នាក់ ភាគហ៊ុនសរុបចំនួន ៥១២ភាគហ៊ុន និងមានទុនសហគមន៍កសិកម្មសរុបចំនួន ១០២,៨០០,០០០រៀល (មួយរយពីរលានបួនរយពាន់រៀលគត់)។

៤. សហគមន៍អភិវឌ្ឍន៍កសិកម្ម សាមគ្គីភូមិទួល បច្ចុប្បន្នមានអសយដ្ឋាននៅភូមិទួល ឃុំអរបួន ស្រុកកោះញែក ខេត្តមណ្ឌលគិរី ដែលមានសមាជិកសរុបចំនួន ២៣នាក់ ក្នុងនោះស្រីសរុបចំនួន ០៥នាក់ ភាគហ៊ុនសរុបចំនួន ៣៨ភាគហ៊ុន និងមានទុនសហគមន៍កសិកម្មសរុបចំនួន ១០៩,០១២,៨០០ រៀល (មួយរយប្រាំបួនលានដប់ពីរពាន់ប្រាំបីរយរៀលគត់ ) ។

៥. **សហគមន៍កសិកម្ម សាមគ្គីមនោរម្យ** ចុះបញ្ជីក្រោមលេខ ម.គ/ស.ក.ក ០០៥/២០១៦ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១៦ មានអសយដ្ឋាននៅភូមិចំការតែ សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ដែលមានសមាជិកសរុបចំនួន ១៥នាក់ ក្នុងនោះស្រីសរុបចំនួន ០៥នាក់ ភាគហ៊ុនសរុបចំនួន ១៧ភាគហ៊ុន និងមានទុនសហគមន៍កសិកម្មសរុបចំនួន ២,៥២០,០០០ រៀល (ពីរលានប្រាំសិបពីរម៉ឺនរៀលគត់ ) ។

៦. **សហគមន៍កសិកម្ម អភិវឌ្ឍមានជ័យ** ចុះបញ្ជីក្រោមលេខ ម.គ/ស.ក.ក ០០៦/២០១៧ ចុះថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០១៧ មានអសយដ្ឋាននៅភូមិមានជ័យ ឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគិរី ដែលមានសមាជិកសរុបចំនួន ៥០នាក់ ក្នុងនោះស្រីសរុបចំនួន ៣០នាក់ មានភាគហ៊ុនសរុបចំនួន ៦០ភាគហ៊ុន និងមានទុនសហគមន៍កសិកម្មសរុបចំនួន ៣.៤០០.០០០ រៀល (បីលានសែសិបម៉ឺនរៀលគត់ ) ។

## II. អំពីការកសាងសមត្ថភាពមន្ត្រី

- ថ្ងៃទី១៦ ខែមិថុនាឆ្នាំ២០១៧ បានចូលរួមវេទិកាពិគ្រោះយោបល់លើកទី២ស្តីពី កិច្ចអភិវឌ្ឍន៍សហគមន៍កសិកម្មនៅកម្ពុជា ជាមួយសមាជិកបណ្តាញភ្នាក់ងារអភិវឌ្ឍន៍សហគមន៍កសិកម្ម នៅភោជនីដ្ឋានទន្លេបាសាក់II រាជធានីភ្នំពេញ ចូលរួមដោយ មន្ទីរកសិកម្មទាំង ២៥ខេត្ត ក្រុង និងអង្គការដៃគូដែលមានអ្នកចូលរួមសរុបចំនួន ១០០នាក់ ក្នុងនោះស្រីចំនួន ១៥នាក់ ។
- ថ្ងៃទី២៥-២៦ ខែកក្កដា ឆ្នាំ ២០១៧ បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី ការត្រួតពិនិត្យផ្ទៃក្នុងរបស់សហគមន៍កសិកម្ម ដែលចូលរួមដោយមន្ទីរកសិកម្ម ២១ខេត្ត ក្រុង នៅអគ្គនាយកដ្ឋានកសិកម្មដែលមានអ្នកចូលរួមសរុបចំនួន ៦៣នាក់ ក្នុងនោះស្រីចំនួន ១១នាក់ ។

## III. កិច្ចសហការ និងបណ្តុះបណ្តាល

- ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៧ បានចូលរួម មហាសន្និបាតប្រចាំឆ្នាំ២០១៦ របស់សហគមន៍សាមគ្គីភូមិទួល ស្ថិតនៅភូមិទួល ឃុំអរប្បូនលើ ស្រុកកោះញែក ដែលមានសមាជិកសហគមន៍កសិកម្មចូលរួមសរុបចំនួន ២៣នាក់ ក្នុងនោះស្រីសរុបចំនួន ១៥នាក់ ។
- ថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៧ បានចូលរួមបិទបញ្ជីប្រចាំឆ្នាំ២០១៦ របស់សហគមន៍កសិកម្មសាមគ្គីមនោរម្យ ស្ថិតនៅភូមិស្រែហ៊ុយ ឃុំស្រែហ៊ុយ ស្រុកកោះញែក ដែលមានសមាជិកសហគមន៍កសិកម្មចូលរួមសរុបចំនួន ៣៨នាក់ ក្នុងនោះស្រីសរុបចំនួន ២៩នាក់ ។
- ថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៧ បានចូលរួមបិទបញ្ជីប្រចាំឆ្នាំ២០១៦ របស់សហគមន៍កសិកម្មសាមគ្គីមនោរម្យ ស្ថិតនៅភូមិចំការតែ សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ដែលមានសមាជិកសហគមន៍កសិកម្មចូលរួមសរុបចំនួន ១៨នាក់ ក្នុងនោះស្រីសរុបចំនួន ០៨នាក់ ។
- ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ បានសហការជាមួយអង្គការ DPA រៀបចំបើកវគ្គបណ្តុះបណ្តាលស្តីពី គោលគំនិតសហគមន៍កសិកម្ម ដល់កសិករស្ថិតនៅភូមិមានជ័យ ឃុំស្រែសង្គម ស្រុកកោះញែក ដែលមានកសិករចូលរួមសរុបចំនួន ២៣នាក់ ក្នុងនោះស្រីសរុបចំនួន ១០នាក់ ។
- ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ បានសហការជាមួយអង្គការ DPA រៀបចំបើកវគ្គបណ្តុះបណ្តាលស្តីពី ច្បាប់សហគមន៍កសិកម្ម ដល់កសិករស្ថិតនៅភូមិមានជ័យ ឃុំស្រែសង្គម ស្រុកកោះញែក ដែលមានកសិករចូលរួមសរុបចំនួន ៣៧នាក់ ក្នុងនោះស្រីសរុបចំនួន ២១នាក់ ។
- ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ បានសហការជាមួយអង្គការ DPA រៀបចំបើកកិច្ចប្រជុំជាមួយកសិករស្តីពី ការធ្វើសេចក្តីសម្រេចចិត្តក្នុងការបង្កើតសហគមន៍កសិកម្មថ្មី ដល់កសិករស្ថិតនៅភូមិមានជ័យ ឃុំស្រែសង្គម ស្រុកកោះញែក ដែលមានកសិករចូលរួមសរុបចំនួន ២៣នាក់ ក្នុងនោះស្រីសរុបចំនួន ១៨នាក់ ។

- ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ បានចូលរួមក្នុងពិធីមហាសន្និបាតប្រចាំឆ្នាំ២០១៦ របស់សហគមន៍អភិវឌ្ឍន៍កសិកម្មសិរីមានរិទ្ធ ស្ថិតនៅភូមិសិរីមានរិទ្ធ ឃុំស្រែសង្គម ស្រុកកោះញែក ដែលមានកសិករចូលរួមសរុបចំនួន ៥១នាក់ ក្នុងនោះស្រីសរុបចំនួន ៣២នាក់ ក្រោមអធិបតីភាពលោក សុង ឃាង ប្រធានមន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ខេត្តមណ្ឌលគិរី ។

- ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៧ បានសហការជាមួយអង្គការ DPA រៀបចំបើកវគ្គបណ្តុះបណ្តាលស្តីពីការធ្វើលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ដើម្បីត្រៀមបើកមហាសន្និបាតកំណើតដំបូងរបស់សហគមន៍កសិកម្មថ្មី ដល់កសិករស្ថិតនៅភូមិមានជ័យ ឃុំស្រែសង្គម ស្រុកកោះញែក ដែលមានកសិករចូលរួមសរុបចំនួន ២៥នាក់ ក្នុងនោះស្រីសរុបចំនួន ១៨នាក់ ។

- ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៧ បានសហការជាមួយអង្គការ DPA រៀបចំបើកមហាសន្និបាតកំណើតដំបូងដល់សហគមន៍កសិកម្មអភិវឌ្ឍន៍មានជ័យ ស្ថិតនៅភូមិមានជ័យ ឃុំស្រែសង្គម ស្រុកកោះញែក ដែលមានកសិករចូលរួមសរុបចំនួន ៥២នាក់ ក្នុងនោះស្រីសរុបចំនួន ៣៥នាក់ ក្រោមអធិបតីភាពលោក សុង ឃាង ប្រធានមន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ខេត្តមណ្ឌលគិរី ។

- ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ បានសហការជាមួយអង្គការ DPA ដើម្បីរៀបចំឯកសារស្នើសុំចុះបញ្ជីសហគមន៍កសិកម្មអភិវឌ្ឍមានជ័យ (ថ្មី) ដល់កសិករស្ថិតនៅភូមិមានជ័យ ឃុំស្រែសង្គម ស្រុកកោះ ខេត្តមណ្ឌលគិរី ។

- ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៧ បានជួបពិភាក្សាជាមួយអង្គការ ICSO ស្តីពីធ្វើផែនការសកម្មភាពបណ្តុះបណ្តាលដល់កសិករ ដើម្បីបង្កើតសហគមន៍កសិកម្មថ្មី នៅមន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ខេត្តមណ្ឌលគិរី ។

- ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៧ បានសហការជាមួយអង្គការ ICSO បើកវគ្គបណ្តុះបណ្តាលដល់កសិករស្តីពី គោលគំនិតសហគមន៍កសិកម្ម ដើម្បីបង្កើតសហគមន៍កសិកម្មថ្មី នៅភូមិ ក្រង់តេះ ឃុំក្រង់តេះ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ដែលមានកសិករចូលរួមសរុបចំនួន ២៧នាក់ ក្នុងនោះស្រីចំនួន ២០នាក់ ។

- ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧ បានសហការជាមួយអង្គការ ICSO បើកវគ្គបណ្តុះបណ្តាលដល់កសិករស្តីពី គោលគំនិតសហគមន៍កសិកម្ម ដើម្បីបង្កើតសហគមន៍កសិកម្មថ្មី នៅភូមិត្រាំកាច់ ឃុំក្រង់តេះ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ដែលមានកសិករចូលរួមសរុបចំនួន ២៨នាក់ ក្នុងនោះស្រីចំនួន ២១នាក់ ។

- ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ បានសហការជាមួយអង្គការ ICSO បើកវគ្គបណ្តុះបណ្តាលដល់កសិករស្តីពី គោលគំនិតសហគមន៍កសិកម្ម ដើម្បីបង្កើតសហគមន៍កសិកម្មថ្មី នៅភូមិពូរ៉ាប៉ែត ឃុំក្រង់តេះ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ដែលមានកសិករចូលរួមសរុបចំនួន ៤៥នាក់ ក្នុងនោះស្រីចំនួន ៣៦នាក់ ។

- ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៧ បានសហការជាមួយអង្គការ DPA បានធ្វើពិធីប្រគល់វិញ្ញាបនបត្រដល់សហគមន៍កសិកម្មអភិវឌ្ឍមានជ័យ (ថ្មី) ដែលស្ថិតនៅភូមិមានជ័យ ឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគិរី ដែលមានសមាជិក សមាជិការចូលរួមសរុបចំនួន ៤៩នាក់ ក្នុងនោះស្រីចំនួន ២៨នាក់ ។

- ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០១៧ បានសហការជាមួយអង្គការ Good Neighbors បើកវគ្គបណ្តុះបណ្តាលស្តីពីការផ្សព្វផ្សាយគោលគំនិតសហគមន៍កសិកម្មដែលមានកសិករចូលរួមមកពីឃុំចំនួនពីរគឺឃុំអរបួនលើ និងឃុំសុខសាន្ត ស្រុកកោះញែកដែលមានអ្នកចូលរួមចំនួន៤០នាក់ក្នុងនោះស្រីចំនួន ២២នាក់។

- ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០១៧ បានសហការជាមួយអង្គការ Good Neighbors បើកវគ្គបណ្តុះបណ្តាលស្តីពីច្បាប់សហគមន៍កសិកម្ម ដែលមានកសិករចូលរួមមក ពីឃុំចំនួនពីរគឺឃុំអរបួនលើ និងឃុំសុខសាន្ត

ស្រុកកោះញ៉ែកដែលមានអ្នកចូលរួមចំនួន ៣០នាក់ ក្នុងនោះស្រីចំនួន ១៣ នាក់។

- ថ្ងៃទី១៧ ខែកក្កដាឆ្នាំ ២០១៧ បានសហការជាមួយអង្គការ Good Neighbors ប្រជុំស្តីពីការធ្វើលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ថ្មីដល់កសិករមកពីឃុំចំនួនពីរគឺឃុំអរបួនលើ និងឃុំសុខសាន្ត ស្រុកកោះញែកដែលមានអ្នកចូលរួមចំនួន២៦នាក់ក្នុងនោះស្រីចំនួន១៣នាក់។

- ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០១៧ បានសហការជាមួយអង្គការ ICSO ប្រជុំផ្សព្វផ្សាយស្តីពីច្បាប់សហគមន៍កសិកម្ម ដល់កសិករដែលមកពី ភូមិក្រង់តេះ ភូមិត្រាំកាច់ ភូមិពូរ៉ាដែត ឃុំក្រង់តេះ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី និងមានកសិករចូលរួមសរុបចំនួន ៤៥នាក់ ក្នុងនោះស្រីចំនួន២៩នាក់ ។

សេចក្តីដូចបានជម្រាបជូនខាងលើនេះ សូមលោកប្រធានមេត្តាពិនិត្យ និងជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះ ។

សូមលោកប្រធាន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីរូបខ្ញុំបាទ !

មណ្ឌលគិរី, ថ្ងៃទី............ខែ...........ឆ្នាំ...........

**ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម**

**មន្ត្រីទទួលបន្ទុករួម**